**MEDIA ADVISORY**

# សេចក្តីប្រកាសព័ត៌មាន

## សម្រាប់ទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទ (IDAHO-T)
## ថ្ងៃសៅរ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០១៤

### សេចក្តីថ្លែងការណ៍រួមរបស់អ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គណៈកម្មការអន្តរអាមេរិកកាំងទទួលបន្ទុកសិទ្ធិមនុស្ស គណៈកម្មការអាហ្វ្រិក ទទួលបន្ទុកសិទ្ធិមនុស្ស និង សិទ្ធិរបស់ប្រជាជន និង តំណាង OSCE ទទួលបន្ទុកសេរីភាពប្រព័ន្ធផ្សព្វផ្សាយ
### "ការបញ្ចេញមតិដោយសេរី និង សមាគម ជាគន្លឹះក្នុងការលុបបំបាត់ការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទ"

ហ្សឺណែវ (១៥ ឧសភា ២០១៤) – *ដោយប្រារព្ធទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទ (IDAHO-T) អ្នកជំនាញការសិទ្ធិមនុស្សអន្តរជាតិ និងថ្នាក់តំបន់មួយក្រុម អំពាវនាវឲ្យរដ្ឋទាំងឡាយបញ្ចប់ការរើសអើង និង ដោះស្រាយបញ្ហាការរំលោភប្រឆាំងនឹងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ព្រមទាំងអ្នកដែលតស៊ូមតិសម្រាប់សិទ្ធិរបស់គេ។*

នៅក្នុងផ្នែកជាច្រើននៃពិភពលោក មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ប្រឈមមុខនឹងការរើសអើង ការប្រមាថមើលងាយ និង អំពើងហិង្សា។ ការការពារ និង ការលើកម្ពស់សិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ក្នុងការបញ្ចេញមតិ ដោយសេរី ខាងសមាគម និង ការរជួបជុំដោយសន្តិវិធី គឺមានលក្ខណៈសំខាន់ក្នុងការបញ្ចប់ការរើសអើង និង ដោះស្រាយការបំពានសិទ្ធិមនុស្សគួរឲ្យរន្ធត់ដែលធ្វើឡើងលើពួកគេ។

**Office of the High Commissioner for Human Rights**
Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org
For further information, visit: www.cambodia.ohchr.org

ទាំងនេះមិនមែនត្រឹមតែជាសិទ្ធិជាមូលដ្ឋានទេ ប៉ុន្តែថែមទាំងជាសិទ្ធិសំខាន់ផងដែរក្នុងការអនុញ្ញាតឲ្យបុគ្គលទាមទារសិទ្ធិផ្សេងទៀតរបស់គេ ជាពិសេសសិទ្ធិសេរីភាពរួចផុតពីការរើសអើង និង សមភាពចំពោះមុខច្បាប់ ហើយពួកគេអាចរួមចំណែកជំរុញការពិភាក្សាជាសាធារណៈក្នុងសង្គម។

យើងសូមថ្កោលទោសអំពើសងសឹង បំភិតបំភ័យ ឬ យាយី ក្នុងកន្លែងណាមួយ (ទោះក្នុងទីសាធារណៈ ឬ ឯកជន) ផ្អែកលើការបង្ហាញ ឬ ការសំដែរបស់គេអំពីទំនោរផ្លូវភេទ អត្តសញ្ញាណផ្លូវភេទ ឬ បង្ហាញយេនឌ័រ។

នៅក្នុងឱកាសទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នា និង មនុស្សប្តូរភេទ (IDAHO-T) ឆ្នាំ ២០១៤ យើងសូមរំលឹកដល់រដ្ឋទាំងឡាយអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារ លើកកម្ពស់ និងបំពេញសិទ្ធិសកលដោយគ្មានការរើសអើង។ អត្ថិភាពនៃការមិនយល់ស្របសង្គមពីទំនោរផ្លូវភេទចម្រុះគ្នា និង អត្តសញ្ញាណយេនឌ័រ មិនមានមូលហេតុសម្រាប់ការរើសអើង ឬ អំពើហិង្សាប្រឆាំងនឹងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ។

ដូច្នេះ យើងមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអត្ថិភាព និងការអនុម័តច្បាប់ថ្មីៗក្នុងប្រទេសជាច្រើន ដែលហាមឃាត់ការផ្សព្វផ្សាយព័ត៌មានពីទំនោរផ្លូវភេទ ឬអត្តសញ្ញាណផ្លូវភេទ និង រឹតត្បិតសិទ្ធិសេរីភាពផ្នែកសមាគម និង ការជួបជុំដោយសន្តិវិធី ដោយបំបាន។

យើងសូមបដិសេធជាដាច់ខាតចំពោះការលើកឡើងដែលថា ការរឹតត្បិតសិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ មានភាពចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ សុខភាព ឬសុខុមាលភាពរបស់អ្នករងគ្រោះ។ ផ្ទុយមកវិញ ច្បាប់ទាំងនេះលើកទឹកចិត្តឲ្យមានការប្រមាថមើលងាយ ការរំលោភបំពាន និង ហិង្សាលើមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ។ ការហាមឃាត់សិទ្ធិទទួលបានព័ត៌មានទាក់ទងសុខភាព ប៉ះពាល់ដល់សុខុមាលភាពផ្លូវកាយ និង ផ្លូវចិត្តរបស់សង្គមទាំងមូល។

អ្នកការពារសិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ជួបប្រទះការប្រឈមមុខធ្ងន់ធ្ងរ ខណៈពេលអនុវត្តការងាររបស់គេ រួមមានការគម្រាមកំហែង ការវាយប្រហារ ការចាត់ទុកជាបទល្មើសនូវសកម្មភាពរបស់គេ និង យុទ្ធនាការបរិហារកេរ្តិ៍។ ម្យ៉ាងវិញទៀត ការជួបជុំ ការប្រមូលផ្តុំ និង ព្យុហយាត្រាដោយសន្តិវិធីរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា

**Office of the High Commissioner**
**for Human Rights**

Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org

For further information, visit:
www.cambodia.ohchr.org

មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ជាញឹកញាប់ត្រូវបានហាមឃាត់ និង កម្រិតឲ្យធ្វើនៅកន្លែងផុតពីការមើលឃើញរបស់សាធារណជន។ ក្នុងប្រទេសជាច្រើន សុវត្ថិភាពរបស់អ្នកចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ ជារឿយៗ មិនត្រូវបានការពារគ្រប់គ្រាន់ពីអាជ្ញាធរជាអ្នកអនុវត្តច្បាប់ទេ។ ក្រៅពីនេះ អង្គការដែលតស៊ូមតិសម្រាប់សិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ស្ថិតក្នុងការត្រួតពិនិត្យហួសហេតុរបស់រដ្ឋ ហើយប្រឈមមុខការឆ្នក់ចូលផាកពិន័យ ការកំហែងយក និង ការបិទ ដោយបំពាន និង រើសអើង។

ទោះបីមានការកើនឡើងចំនួនរដ្ឋដែលបាននិរករណ៍ច្បាប់ និង លុបបំបាត់គោលនយោបាយដែលរើសអើងមនុស្សដោយសារទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រនោះ ប្រទេសចំនួន ៧៧ នៅតែចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងដែលមានការព្រមព្រៀងរវាងនីតិជនដែលមានភេទដូចគ្នា។ ប្រទេសខ្លះចាត់ទុកជាបទល្មើសចំពោះអត្តសញ្ញាណ និងការសំដែងយេនឌ័រ ដែលប៉ះពាល់ដល់មនុស្សប្តូរភេទ។ ច្បាប់រើសអើងបែបនេះបំពានបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ធ្វើឲ្យហិង្សា និង ការរើសអើងលើមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ កាន់តែក្តៅឡើង រួមចំណែកចំពោះវប្បធម៌និទណ្ឌភាព និង ធ្វើឲ្យបរិយាកាសមានអរិភាព។ ច្បាប់ទាំងនេះគួរតែលុបចោល។

រដ្ឋទាំងឡាយត្រូវកសាងបរិយាកាសអត់ឱន និង គោរពដែលមនុស្សទាំងអស់ រួមទាំងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ និង អ្នកការពារសិទ្ធិរបស់ខ្លួន អាចសំដែងគំនិត និង ទស្សនៈរបស់គេ ដោយគ្មានការភ័យខ្លាចពីការវាយប្រហារ ប្រព្រឹត្តអំពើជាបទល្មើស ឬ ប្រមាថមើលងាយ ដោយសារធ្វើបែបនេះ។ រដ្ឋត្រូវត្រូវធានាពីការចូលរួមក្នុងកិច្ចការសាធារណៈរបស់អ្នកដែលជាធម្មតារងការអនុវត្ត ឬ គោលនយោបាយរើសងអើង។

ហេតុនេះ យើងសូមអំពាវនាវឲ្យរដ្ឋទាំងឡាយបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងនៅក្នុងស្ថាប័នអន្តររដ្ឋាភិបាលក្នុងតំបន់ និង ដើម្បីអនុលោមតាមកាព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនក្នុងការការពារ លើកកម្ពស់ និង បំពេញសិទ្ធិទាំងអស់គ្នា ដោយគ្មានការរើសអើង។

បញ្ចប់

**Office of the High Commissioner**
**for Human Rights**

Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org

For further information, visit:
www.cambodia.ohchr.org

# MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

(*)**ក្រុមអ្នកជំនាញការៈ** លោក Frank La Rue អ្នករាយការណ៍ពិសេសផ្នែកលើកកម្ពស់ និង ការពារសិទ្ធិសេរីភាពនៃគំនិត និង បញ្ចេញមតិ។ លោក Maina Kiai អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិសេរីភាពនៃការជួបជុំគ្នាដោយសន្តិវិធី និង សមាគម។លោក Anand Grover អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានសុខភាពផ្លូវកាយ និង ផ្លូវចិត្ត ក្នុងកម្រិតខ្ពស់បំផុតដែលអាចទទួលយកបាន។លោកស្រី Margaret Sekaggya អ្នករាយការណ៍ពិសេសផ្នែកស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។

អ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គឺជាផ្នែកនៃអ្វីដែលគេដឹងថាជានីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។នីតិវិធីពិសេស ជាស្ថាប័នធំជាងគេបំផុតនៃអ្នកជំនាញការឯករាជ្យផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គឺជាឈ្មោះទូទៅនៃយន្តការត្រួតពិនិត្យ និង ស្វែងរកការពិតឯករាជ្យនៃក្រុមប្រឹក្សាសិទ្ធិមនុស្សដែលដោះស្រាយស្ថានការរបស់ប្រទេសជាក់លាក់ណាមួយ ឬ បញ្ហាជាប្រធានបទគ្រប់ផ្នែកនៃពិភពលោក។ សូមសិក្សាបន្ថែមតាមhttp://www.ohchr.org/EN/HRBodies/SP/Pages/
Welcomepage.aspx។

ស្ថាបន័ស្វយ័ត សំខាន់របស់អង្គការរដ្ឋអាមេរិក (OAS) IACHR ទទួលអាណត្តិពីធម្មនុញ្ញ OAS និង អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស។ គណៈកម្មាធិការអន្តរអាមេរិកកាំងមានអាណត្តិលើកកម្ពស់ការគោរពសិទ្ធិមនុស្សក្នុងតំបន់ និង ធ្វើជាស្ថាប័នពិគ្រោះយោបល់ឲ្យ OAS ក្នុងតំបន់នេះ។ គណៈកម្មការមានសមាសភាពពីសមាជិកឯករាជ្យប្រាំពីរនាក់ដែលបានជ្រើសរើសដោយមហាសន្និបាត OAS និង ដែលមិនតំណាងប្រទេសដើម ឬ កន្លែងរស់នៅរបស់គេ។ សូមសិក្សាបន្ថែមតាម http://www.achpr.org/។

គណៈកម្មការអាហ្វ្រិក ទទួលបន្ទុកសិទ្ធិមនុស្ស និង សិទ្ធិរបស់ប្រជាជន ត្រូវបានបង្កើតឡើងដោយធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និង សិទ្ធិរបស់ប្រជាជន ។ គណៈកម្មការមានសមាជិក ១១ នាក់ដែលបានជ្រើសរើសដោយមហាសន្និបាត AU ក្នុងចំណោមអ្នកជំនាញការតែងតាំងដោយរដ្ឋជាភាគីនៃធម្មនុញ្ញ។គណៈកម្មការបង្កើតយន្តការបន្ទាប់បន្សំ ដូចជា អ្នករាយការណ៍ពិសេស គណៈកម្មាធិការ និង ក្រុមការងារដើម្បីសម្រេចបាននូវគោលបំណងនៃការលើកកម្ពស់ និង ការពារសិទ្ធិមនុស្សលើឧបទ្វីប។ អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដោយគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និង សិទ្ធិរបស់ប្រជាជន ដោយសេចក្តីសម្រេចលេខ ៦៩ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៣៥ ក្នុង បាន់ជុល នៃប្រទេសហ្គាំប៊ា ពីថ្ងៃទី ២១ ខែ ឧសភា ដល់ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០៤។ សូមសិក្សាបន្ថែមតាម http://www.achpr.org/។

**Office of the High Commissioner for Human Rights**
Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org
For further information, visit: www.cambodia.ohchr.org

# MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

តំណាង OSCE ទទួកបន្ទុកសេរីភាព និង ប្រព័ន្ធផ្សព្វផ្សាយគាំទ្រដល់សេចក្តីថ្លែងការណ៍នេះក្នុងករណីវាយោងលើផ្នែកស្ថិតក្នុងវិសាលភាពនៃអាណត្តិរបស់គាត់។

ព័ត៌មានបន្ថែម និង សំណូមពរផ្នែកប្រព័ន្ធផ្សព្វផ្សាយ សូមទាក់ទង:

អ្នកជំនាញការអង្គការសហប្រជាជាតិ: Ms. Dolores Infante-Cañibano (+41 22 917 9730 / dinfante@ohchr.org) or Ravina Shamdasani (+41 22 917 9169 /rshamdasani@ohchr.org)

OSCE Representative : Mr. Gunnar Vrang (gunnar.vrang@osce.org)

សិទ្ធិមនុស្សអង្គការសហប្រជាជាតិ តាមដានជាមួយយើងអំពីប្រព័ន្ធផ្សព្វផ្សាយសង្គម:

Facebook:https://www.facebook.com/unitednationshumanrights
Twitter: http://twitter.com/UNrightswire
Google+ gplus.to/unitednationshumanrights

**Office of the High Commissioner**
**for Human Rights**

Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org

For further information, visit:
www.cambodia.ohchr.org